# បាលីវេរសង្ឃភត្ត

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ សង្ឃភត្តំ សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តាទយោ ឥមំ សង្ឃភត្តំ អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិត សម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន។

ទុតិយម្បិ អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ សង្ឃភត្តំ សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តាទយោ ឥមំ សង្ឃភត្តំ អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិត សម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន។

តតិយម្បិ អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ សង្ឃភត្តំ សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តាទយោ ឥមំ សង្ឃភត្តំ អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិត សម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន។

*បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើនទ្បើយ វីចង្ហាន់បិណ្ឌបាត្រនៃ យើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះលោក អ្នកដ៏មាន គុណទាំងឡាយ មានមាតាបិតាជាដើម ហើយយើងខ្ញុំទាំងឡាយ វេរនូវសង្ឃភត្តនេះ ព្រមទាំងបរិក្ខារ ប្រគេនចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោអ្នកដ៏មាន គុណទាំងឡាយ មានមាតាបិតាជា*



*ដើមនោះ សម្គាល់នូវសង្ឃភត្តនេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយបីប្រការ គឺសម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នារបស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្សដែលហូរជូនទៅមិនដាច់នេះហោង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។*

**បញ្ជាក់** : *ក្នុងសៀវភៅគិហិបដិបត្តិ ពិសេសពិស្តាររបស់ព្រះសីលសំវរ រស់-កែវ លោកបានបញ្ជាក់ប្រាប់ថា៖ បើចង់ថា ទុតិយម្បិ គួរថា ទុតិយម្បិ អយំ នោ ភន្តេ បិណ្ឌបាតោ ។ល ។ រហូតដល់និស្សន្ទេន ។ បើចង់ថា តតិយម្បិ គួរថា អយំ នោ ភន្តេ បិណ្ឌបាតោ ។ល ។ រហូតដល់ និស្សន្ទេន ។ មើលពេលផង, បើពេលខាងមុខខ្លី គួរថា អយំ នោ ភន្តេ បិណ្ឌបាតោ ។ល ។ រហូតដល់ ឥមិនា និស្សន្ទេន ហើយប្រែតទៅ ។ មិនបាច់ថា ទុតិយម្បិ តតិយម្បិទេ ។ បើចង់ថា ទុតិយម្បិ តតិយម្បិ, គួរតែថាឱ្យបានហូរហែដូចលើកទី១ យ៉ាងនេះទើបគួរ ។ ឯរបៀបបាលីវេរទាំងអស់ បើចង់ថា ទុតិយម្បិ, តតិយម្បិ, គួរតែថាឱ្យបានហូរហែដូចលើកទី១ទាំងអស់ដែរ ។*

បើវេរឧទ្ទិសផលជូនចំពោះបិតា គួផ្លាស់បាលីឱ្យទៅជា បុំលិង្គឯកវចនៈ ដូចខាងក្រោមនេះ ៖

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ (*បញ្ចូលឈ្មោះ*) កាលកតស្ស បិតុនោ គុណវន្តស្ស ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេមសោ គុណវា ឥមំ (សង្ឃភត្តំ ) អត្តនោ សន្តកំ វិយ មញ្ញមានោ អនុមោទតុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈតុ សព្វទុក្ខា បមុញ្ចតុ ឥមិនា និស្សន្ទេន ។



ទុតិយម្បិ អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ (បញ្ចូលឈ្មោះ) កាលកតស្ស បិតុនោ គុណវន្តេស្ស ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម សោ គុណវា ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានោ អនុមោទតុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈតុ សព្វទុក្ខា បមុញ្ចតុ ឥមិនា និស្សន្ទេន ។

តតិយម្បិ អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ (បញ្ចូលឈ្មោះ) កាលកតស្ស បិតុនោ គុណវន្តេស្ស ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម សោ គុណវា ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានោ អនុមោទតុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈតុ សព្វទុក្ខា បមុញ្ចតុ ឥមិនា និស្សន្ទេន ។

**ប្រែថា :** *បពិត្រព្រះគម្តែងសង្ឃដ៏ចំរើនទ្បើយ វិចង្ហាន់បិណ្ឌបាត្រ នៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើនដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះលោកអ្នកដ៏មានគុណ គឺបិតា (ឈ្មោះ ---) ដែលធ្វើកាលកិរិយាលះលោកនេះទៅកាន់លោកខាងនាយហើយ យើងខ្ញុំទាំងឡាយវេរនូវ (សង្ឃភត្ត) នេះ ព្រមទាំងបរិវារប្រគេនចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណ (គឺបិតាឈ្មោះ---) នោះ សំគាល់នូវ (សង្ឃភត្ត) នេះថាដូចជារបស់នៃលោក សូមលោកទទួលអនុមោទនាយកចុះ លុះទទួលអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិ ទាំងឡាយ៣ប្រការ គឺសម្បត្តិមនុស្សលោក១ សម្បត្តិទេវលោក១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នារបស់លោកអ្នកដ៏មានគុណនោះចុះ ដោយអំណាចផលានិសង្សដែលហូរជូនទៅមិនដាច់នេះហោង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។*



បើវេរឧទ្ទិសផលជូនចំពោះមាតា គួផ្លាស់បាលីឱ្យទៅជា ឥត្ថីលិង្គឯកវចនៈ ដូចខាងក្រោមនេះ ៖

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ *(បញ្ចូលឈ្មោះ--)* កាលកតាយ មាតុយា គុណវតិយា ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម សា គុណវតី ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានោ អនុមោទតុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈតុ សព្វទុក្ខា បមុញ្ចតុ ឥមិនា និស្សន្ទេន។

ទុតិយម្បិ អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ *(បញ្ចូលឈ្មោះ---)* កាលកតាយ មាតុយា គុណវតិយា ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម សា គុណវតី ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានោ អនុមោទតុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈតុ សព្វទុក្ខា បមុញ្ចតុ ឥមិនា និស្សន្ទេន។

តតិយម្បិ អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ *(បញ្ចូលឈ្មោះ---)* កាលកតាយ មាតុយា គុណវតិយា ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិវារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម សា គុណវតី ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានោ អនុមោទតុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈតុ សព្វទុក្ខា បមុញ្ចតុ ឥមិនា និស្សន្ទេន។

**ប្រែថា** ៖ *បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនទ្បើយ វីចង្ហាន់បិណ្ឌបាត្រ នៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះលោកអ្នកដ៏មានគុណ គឺមាតា (ឈ្មោះ ---) ដែលធ្វើកាលកិរិយាទៅកាន់លោកខាងនាយហើយ យើងខ្ញុំទាំងឡាយវេរនូវ (សង្ឃភត្ត) នេះ ព្រមទាំងបរិវារប្រគេនចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណ (គឺមាតាឈ្មោះ---) សំគាល់នូវ (សង្ឃភត្ត)*



*នេះថាដូចជារបស់នៃលោក សូមលោកទទួលអនុមោទនាយកចុះ លុះទទួលអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិ ទាំងឡាយបីប្រការ គឺ៖ សម្បត្តិមនុស្សលោក១ សម្បត្តិទេវលោក១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នារបស់លោកអ្នកដ៏មានគុណនោះចុះ ដោយអំណាចផលានិសង្សដែលបូរជូនទៅមិនដាច់ នេះហោង ។ អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។*

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ម៉ាន់ អ៊ុន** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វ័រនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២

វត្តធម្មារាម



វត្តធម្មារាម